# ការណែនាំបំភ្លឺអំពី ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម



បោះពុម្ពលើកទីពីរ

# មាតិការឿង

## សំណួរ


**សំណួរទី១:** តើហេតុអ្វីបានជារយៈពេលយូរម្ល៉េះ ទើបចាប់ផ្តើមជំនុំជម្រះបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមកាន់កាប់អំណាច? ............... ៦

**សំណួរទី២:** ហេតុអ្វីបានជាយើងបំរុងធ្វើការកាត់ក្តីក្នុងពេលឆាប់ៗនេះ? តើការកាត់ក្តីខ្មែរក្រហមនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងដូចម្តេចចំពោះប្រជាជនកម្ពុជា? ............... ៧

**សំណួរទី៣:** តើអ្នកណាខ្លះនឹងត្រូវនាំយកមកធ្វើការកាត់ក្តី? ............... ៨

**សំណួរទី៤:** តើជនសង្ស័យនឹងទទួលនូវការដាក់ទោសអ្វីខ្លះ ប្រសិនបើគេត្រូវបានកាត់ក្តីថាមានទោស? ............... ៩

**សំណួរទី៥:** តើមានការលើកលែងទោស ឬការអនុគ្រោះទោសដែរ ឬទេ? ............... ៩

**សំណួរទី៦:** តើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាខ្លះ ដែលត្រូវបានធ្វើការកាត់ក្តីរួចហើយ? ............... ៩

**សំណួរទី៧:** ចុះចំពោះបណ្តាប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ជាប់ពាក់ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យ ឬក៏បណ្តាប្រទេសដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជាមុនឆ្នាំ ១៩៧៥ តើប្រទេសទាំងនោះត្រូវឡើងតុលាការដែរ ឬអត់? ............... ១១

**សំណួរទី៨:** ចុះចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ឬអ្នកដទៃទៀតក្រោយឆ្នាំ ១៩៧៩? ............... ១១

**សំណួរទី៩:** តើការកាត់ក្តីនឹងចាប់ផ្តើមនៅពេលណា? ............... ១៣

**សំណួរទី១០:** តើការកាត់ក្តីនឹងប្រើរយៈពេលប៉ុន្មានឆ្នាំ? ............... ១៣

**សំណួរទី១១:** តើការកាត់ក្តីនេះនឹងត្រូវប្រព្រឹត្តទៅនៅកន្លែងណា? ............... ១៣

**សំណួរទី១២:** តើអង្គជំនុំជម្រះវិសាមញ្ញធ្វើការរបៀបដូចម្តេច? ............... ១៤

**សំណួរទី១៣:** តើអ្នកណាអាចចូលទៅស្តាប់ការកាត់ក្តីបាន? ............... ១៥

**សំណួរទី១៤:** ប្រសិនបើយើងមិនអាចទៅបាន តើធ្វើដូចម្តេចយើងអាចដឹងបានពីអ្វីដែលកំពុងកើតឡើងនៅក្នុងតុលាការ? ............... ១៧

**សំណួរទី១៥:** តើចៅក្រមនឹងត្រូវតែងតាំងឡើងយ៉ាងដូចម្តេច? ............... ១៧



**គំរបជារូបភាព :** ខេត្តស្វាយរៀង ឆ្នាំ ១៩៨៣ ។ ផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

**ការណែនាំបំភ្លឺអំពី ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម** ត្រូវបានរៀបចំឡើងដោយ លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលនៅទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយបានទទួលនូវជំនួយសប្បុរសពីអង្គការធនធានច្បាប់អន្តរជាតិអូស្រ្តាលី Australian Legal Resources International (ALRI) ក្នុងនាមទីភ្នាក់ងារអូស្រ្តាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ Australian Agency for Internation Development (AusAid) ។



សិទ្ធិក្នុងការចំលងបោះពុម្ពផ្សាយជាថ្មីទាំងស្រុង ឬក៏មួយផ្នែកនៃកូនសៀវភៅនេះ សំរាប់គោលបំណងមិនទាញយកចំណេញ ត្រូវបានផ្តល់ជូន និងលើកទឹកចិត្ត ក្នុងករណីដែលការចំលងត្រូវមានថែងពីចំណាងដើង ប្រភពព័ត៌មាន និងម្ចាស់ជំនួយរបស់កូនសៀវភៅនេះ ។

**រក្សាសិទ្ធិគ្រប់យ៉ាង ឆ្នាំ ២០០៦**

**សំណួរទី១៦:** តើអង្គចៅក្រមនឹងឈានដល់ការចេញសេចក្តីសំរេចរួម យ៉ាងដូចម្តេច? ....... ១៧

**សំណួរទី១៧:** តើអ្នកណាជាអ្នកសំរេចថា តើអ្នកណាខ្លះនឹងត្រូវកាត់សេចក្តី? តើអ្នកណាជាអ្នកសំរេចថា តើពួកគេនឹងត្រូវចោទប្រកាន់ ពីបទល្មើសអ្វី? ....... ១៨

**សំណួរទី១៨:** តើមានអ្វីកើតឡើង ប្រសិនបើសហព្រះរាជអាជ្ញា ឬក៏សហចៅក្រមស៊ើបអង្កេតមិនយល់ស្របគ្នាថា តើត្រូវបញ្ជូនរឿងក្តីណាមួយ ទៅធ្វើការកាត់សេចក្តី ឬក៏អត់? ....... ១៨

**សំណួរទី១៩:** តើចៅក្រមនៅសាលាដំបូងធ្វើការងារអ្វីខ្លះ? ....... ១៨

**សំណួរទី២០:** តើភស្តុតាងអ្វីខ្លះ នឹងត្រូវប្រើប្រាស់នៅពេលកាត់សេចក្តី? ....... ២០

**សំណួរទី២១:** តើបទឧក្រិដ្ឋអ្វីនឹងត្រូវធ្វើការកាត់ក្តី? តើការកាត់ក្តី ប្រើច្បាប់កម្ពុជា ឬក៏ច្បាប់អន្តរជាតិ? ....... ២០

**សំណួរទី២២:** តើចុងចោទមានសិទ្ធិអ្វីខ្លះ នៅក្នុងតុលាការជំនុំជម្រះក្តី? ....... ២១

**សំណួរទី២៣:** តើអ្នកណាខ្លះ នឹងកោះអញ្ជើញអោយធ្វើជាសាក្សី? ....... ២២

**សំណួរទី២៤:** តើខ្ញុំត្រូវផ្តល់ព័ត៌មានទៅអោយតុលាការដែរ ឬទេ? ....... ២២

**សំណួរទី២៥:** តើធ្វើយ៉ាងដូចម្តេច ប្រសិនបើខ្ញុំចង់ផ្តល់ព័ត៌មានអំពីនរណាមួយ ដែលខ្ញុំជឿជាក់ថាបានប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ ក្នុងអំឡុងពេលរបបខ្មែរក្រហម? ....... ២២

**សំណួរទី២៦:** តើការគាំទ្រអ្វីខ្លះ នឹងត្រូវផ្តល់ជូនដល់ពលរដ្ឋដែលបានចូលរួម? ... ២២

**សំណួរទី២៧:** តើជនរងគ្រោះមានសិទ្ធិទទួលសំណងទូទាត់ដែរ ឬទេ? ....... ២៣

**សំណួរទី២៨:** តើហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមពាក់ព័ន្ធ? ....... ២៣

**សំណួរទី២៩:** តើហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមមិនត្រូវយកទៅកាត់សេចក្តី នៅទីក្រុងឡាអេ ដែលជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬក្នុងតុលាការយុត្តិធម៌អន្តរជាតិ? ....... ២៤

**សំណួរទី៣០:** តើអង្គជំនុំជម្រះវិសាមញ្ញនេះ គឺជាតុលាការកម្ពុជា ឬជាតុលាការអន្តរជាតិ? ....... ២៤

**សំណួរទី៣១:** តើមានតុលាការផ្សេងទៀតដែរ ឬទេ នៅក្នុងពិភពលោក ដែលមានលក្ខណៈដូចអង្គជំនុំជម្រះវិសាមញ្ញនេះ? ....... ២៤

**សំណួរទី៣២:** តើហេតុអ្វីបានជាតុលាការប្រភេទនេះ ត្រូវបានយកមកប្រើ សំរាប់អង្គជំនុំជម្រះវិសាមញ្ញ? ....... ២៤

**សំណួរទី៣៣:** តើត្រូវចំណាយថវិកាប៉ុន្មាន សំរាប់ដំណើរការកាត់ក្តីនេះ? ....... ២៥

**សំណួរទី៣៤:** តើតុលាការនេះនឹងត្រូវទទួលថវិកាពីប្រភពណា? ....... ២៥

**សំណួរទី៣៥:** តើដោយវិធីណាដែលខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីខ្មែរក្រហម និងដំណើរការកាត់សេចក្តីនេះ? ....... ២៦

**សំណួរទី៣៦:** តើអង្គការក្រៅរដ្ឋាភិបាលមានតួនាទីអ្វីខ្លះ? ....... ២៧

**សំណួរទី៣៧:** តើខ្ញុំអាចទទួលសេវាកម្មគាំទ្រនៅទីណា? ....... ២៧



# អារម្ភកថា

**ដោយសម្តេច ហ៊ុន សែន**

*នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា*

**បងប្អូនរួមជាតិជាទីស្នេហា !**

គ្មានប្រជាជនយើងណាម្នាក់ បានគេចផុតពីការបំផ្លិចបំផ្លាញដែលប្រព្រឹត្តមកលើមាតុភូមិជាទីស្នេហារបស់យើង ក្នុងអំឡុងពេល ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ ដែលពួកខ្មែរក្រហម ប៉ុល ពត កាន់អំណាចនៅក្រោមរបបមួយដែលគេស្គាល់ឈ្មោះថា កម្ពុជាប្រជាធិបតេយ្យ ។

ក្នុងរយៈពេលនោះ ប្រជាជនយើងជាង ៣ លាននាក់ បានបាត់បង់ជីវិត ។ អ្នកទាំងនោះ គឺជាពុកម៉ែរបស់យើង កូន សាច់ញាតិ មិត្តរួមការងារ (សហសេវិក) និងមិត្តភក្តិយើង ។ ពួកយើងដែលនៅសល់ពីស្លាប់ បានរស់នៅអស់រយៈពេលជាង ២៥ ឆ្នាំ ដោយក្តីឈឺចាប់ ខ្លោចផ្សា សោកសង្រេង ដល់អ្នកដែលបានបាត់បង់ជីវិតទៅហើយ និងសុបិនអាក្រក់នៃអនុស្សាវរីយ៍ដ៏ជូរចត់របស់យើងតាមលងឥតស្រាកស្រាន្ត ។

សូម្បីតែបងប្អូនរួមជាតិដែលកើតក្រោយឆ្នាំ ១៩៧៩ ដែលមិនបានជួបប្រទះផ្ទាល់នូវឧក្រិដ្ឋកម្មទាំងនោះ ក៏ទទួលរងនូវបន្ទុកដ៏ធ្ងន់ធ្ងរដែរ ។ បងប្អូនឃើញ ពុកម៉ែ និងសាច់ញាតិប្រុសស្រីរបស់បងប្អូន កំពុងឈឺចាប់ខ្លោចផ្សានៅឡើយ ។ បងប្អូនក៏រួមចំណែកផងដែរនូវរាល់ការលំបាកក្នុងការកសាងសង្គមជាតិយើងឡើងវិញពីបាតដៃទទេ ឬឆ្នាំសូន្យដោយមិនបានទទួលអត្ថប្រយោជន៍នៃគតិបណ្ឌិត និងបទពិសោធន៍ពីញាតិមិត្តដែលបានស្លាប់ទៅហើយ ។

យើងបាន និងកំពុងតស៊ូយ៉ាងខ្លាំងក្លា ដើម្បីស្តារប្រទេសជាតិឡើងវិញ ហើយយើងទាំងអស់គ្នាដឹងថា កម្ពុជាសព្វថ្ងៃនេះ មានលក្ខណៈអន់ថយឆ្ងាយពីបណ្តាប្រទេសជិតខាងក្នុងវិស័យសុខាភិបាល អប់រំ និងប្រាក់ចំណូល (ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច) ។

ឥឡូវនេះ ពេលវេលាបានមកដល់ហើយ សំរាប់អ្នកទាំងឡាយណាដែលទទួលខុសត្រូវក្នុងការរៀបចំផែនការ និងបញ្ជាអោយមានការប្រព្រឹត្តឧក្រិដ្ឋកម្មព្រៃផ្សៃ ត្រូវនាំមកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់ពួកគេ ។

ដោយអនុលោមទៅតាមការចរចាជាមួយអង្គការសហប្រជាជាតិអស់រយៈពេលជាច្រើនឆ្នាំ ឥឡូវយើងកំពុងតែនឹងបង្កើតតុលាការកម្ពុជាថ្មីមួយ ដែលរួមបញ្ចូលមន្ត្រីបំរើការងារ និងចៅក្រមអន្តរជាតិ ។ ឈ្មោះជាផ្លូវការរបស់តុលាការនេះ គឺអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នេះ គឺជាតុលាការលើកទីមួយនៅក្នុងពិភពលោកដែលជំនុំជម្រះក្តីបែបនេះ ។

ឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលរបបខ្មែរក្រហម មិនត្រឹមតែបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងប្រឆាំងនឹងមនុស្សជាតិទាំងមូលផងដែរ ។ ដូចនេះ វាសមស្របណាស់ ដែលពលរដ្ឋកម្ពុជា ត្រូវសហការជាមួយសហគមន៍អន្តរជាតិ ដើម្បីជំនុំជម្រះទោសពួកដែលទទួលខុសត្រូវជាងគេបំផុតនៅក្នុងបទឧក្រិដ្ឋ ហើយការធ្វើដូច្នេះ នឹងជួយបង្កើតនូវវប្បធម៌មួយ ដែលទប់ស្កាត់នូវការកើតឡើងសារជាថ្មីនៃឧក្រិដ្ឋកម្មបែបនេះនៅគ្រប់ទិសទីនៃពិភពលោក ។ យើងសង្ឃឹមថា តុលាការថ្មីរបស់យើងនឹងក្លាយទៅជាតុលាការគំរូដ៏ជោគជ័យ ដែលមិនមែនសំរាប់តែកម្ពុជាប៉ុណ្ណោះទេ គឺថែមទាំងផ្តល់វិភាគទានដ៏ទូលំទូលាយដល់យុត្តិធម៌ពិភពលោកផងដែរ ។

ខ្ញុំមានជំនឿថា បងប្អូនរួមជាតិនឹងចូលរួមជាមួយខ្ញុំក្នុងក្តីសង្ឃឹមថា ការជំនុំជម្រះក្តីនេះនឹងប្រព្រឹត្តទៅនៅក្នុងសភាពថ្លៃថ្នូរ និងសន្តិភាព ។ ពេលដែលអង្គចៅក្រមប្រកាសចេញសាលក្រម យើងសង្ឃឹមថា ប្រជាជនកម្ពុជា និងអ្នកទាំងឡាយណាដែលគាំទ្រយើងនឹងឃើញថា នៅទីបញ្ចប់ យើងនឹងនាំមកនូវយុត្តិធម៌ក្នុងនាមនៃជនរងគ្រោះទាំងឡាយ ។

នាយករដ្ឋមន្ត្រី



# សេចក្តីផ្តើម

## ដោយឯកឧត្តម សុខ អាន

ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជាសំរាប់កិច្ចសហប្រតិបត្តិការជាមួយ
អ្នកជំនាញការអន្តរជាតិផ្នែកច្បាប់ និងការត្រៀមរៀបចំដំណើរការកាត់ក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម

របបខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ហើយត្រូវទំលាក់ចុះពីអំណាចនៅថ្ងៃទី ៧ មករា ឆ្នាំ១៩៧៩ ។ ប្រជាជនជាង ៣ លាននាក់ បានបាត់បង់ជីវិត ។ សង្គ្រាមស៊ីវិលបានបន្ត ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ។ នៅទីបំផុត សង្គ្រាមស៊ីវិលបានត្រូវបញ្ចប់នៅឆ្នាំ ១៩៩៨ នៅពេលដែលរចនាសម្ព័ន្ធនយោបាយ និងយោធារបស់ខ្មែរក្រហមត្រូវកំទេចចោល ។

នៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជា បានសំណូមពរអោយអង្គការសហប្រជាជាតិជួយឧបត្ថម្ភបង្កើតសាលាជម្រះក្តី ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ នៅឆ្នាំ ២០០១ រដ្ឋសភាជាតិកម្ពុជា បានអនុម័តច្បាប់មួយ ដើម្បីបង្កើតតុលាការកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅប្រទេសកម្ពុជាក្នុងអំឡុងពេលរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥-១៩៧៩ ។ តុលាការនេះមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (អង្គជំនុំជម្រះវិសាមញ្ញ) ។

រាជរដ្ឋាភិបាលកម្ពុជាបានទទូចសុំថា ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ តុលាការជម្រះក្តីត្រូវប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជាដោយប្រើប្រាស់មន្ត្រី និងចៅក្រមកម្ពុជា គួបផ្សំជាមួយមន្ត្រី និងចៅក្រមអន្តរជាតិ ។ កម្ពុជាបានអញ្ជើញសហគមន៍អន្តរជាតិអោយចូលរួមសហការក្នុងការកាត់សេចក្តីនេះ ដើម្បីធានាអោយមានយុត្តិធម៌ជាលក្ខណៈស្តង់ដារអន្តរជាតិ ព្រោះកម្ពុជាយល់ឃើញថា ខ្លួននៅទន់ខ្សោយផ្នែកតុលាការ និងចរិតលក្ខណៈអន្តរជាតិនៃឧក្រិដ្ឋកម្ម ។ ចុងបញ្ចប់ កិច្ចព្រមព្រៀងមួយជាមួយ

អង្គការសហប្រជាជាតិ ត្រូវបានចុះហត្ថលេខានៅខែ មិថុនា ឆ្នាំ ២០០៣ ដែលចែងថា តើសហគមន៍អន្តរជាតិនឹងជួយឧបត្ថម្ភ និងសហការរៀប ដូចម្តេចនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ។

តុលាការថ្មី ហើយពិសេសនេះ ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ប៉ុន្តែតុលាការនេះ គឺឯករាជ្យម្ចាស់ការ មិនចំណុះអោយរាជរដ្ឋាភិបាល ឬអង្គការសហប្រជាជាតិទេ ។ តុលាការនេះ គឺជាតុលាការកម្ពុជាដែលមានការចូលរួមពីសហគមន៍អន្តរជាតិ ដែលនឹងអនុវត្តទៅតាមស្តង់ដារអន្តរជាតិ ។ តុលាការនេះ នឹងផ្តល់ជាគំរូត្អូនាទីថ្មីមួយសំរាប់ដំណើរការកាត់ក្តីនៅកម្ពុជា ។ នៅពេលដែលកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្តល់សច្ចាប័ន (អនុម័តយល់ព្រម) ពីរដ្ឋសភាជាតិកម្ពុជា នោះតុលាការនេះនឹងត្រូវបង្កើតឡើងនៅកម្ពុជា ។ បន្ទាប់មក គេនឹងបើកការិយាល័យរដ្ឋបាលមួយ ដើម្បីពិភាក្សាបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ហើយនឹងចាប់ផ្តើមការត្រៀមរៀបចំដំណើរការកាត់ក្តីជាផ្លូវការ ។

កូនសៀវភៅនេះ នឹងណែនាំបំភ្លឺលោកអ្នកអំពីអង្គជំនុំជម្រះវិសាមញ្ញ ហើយឆ្លើយតបទៅនឹងសំណួរមួយចំនួន ដែលប្រជាជនខ្សស្រាប់សាកសួរអំពីការជំនុំជម្រះក្តីនេះ ។ ពេលដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើង ផ្នែកពិសេសមួយនៃប្រព័ន្ធផ្សព្វផ្សាយនឹងផ្តល់ជូនព័ត៌មានដល់សាធារណជន ។

ឧបនាយករដ្ឋមន្ត្រី

# សំណួរទី ១

## តើហេតុអ្វីបានជាត្រូវប្រើរយៈពេលយូរម៉្លេះ ទើបចាប់ផ្តើមជំនុំជម្រះបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមកាន់កាប់អំណាច ?

ប្រវត្តិសាស្ត្របានបង្ហាញអោយឃើញថា នៅពេលប្រទេសនៅមានសង្គ្រាម ការធ្វើការកាត់សេចក្តីជួបប្រទះការលំបាកខ្លាំង ។ សង្គ្រាមស៊ីវិលទើបតែបានបញ្ចប់ទៅនៅក្នុងឆ្នាំ ១៩៩៨ ប៉ុណ្ណោះ ។ ចាប់តាំងពីប្រទេសកម្ពុជាស្នើសុំអោយអង្គការសហប្រជាជាតិជួយនៅឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានសហការគ្នាឆ្ពោះទៅរកការអនុវត្តន៍ជាបណ្តើរៗ នូវទំរង់ថ្មីមួយនៃសាលាជនុំជម្រះក្តីចំរុះជាតិ និងអន្តរជាតិ ។ ដូច្នេះ វាត្រូវប្រើរយៈពេលយូរបន្តិច ដើម្បីសិក្សានូវបញ្ហាលំអិតជាច្រើននៃប្រភេទតុលាការគំរូថ្មីមួយនេះ ។

នៅឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជា បានតែងតាំងក្រុមការងារមួយ ដើម្បីរៀបចំការកាត់ក្តី និងធ្វើការចរចាជាមួយអង្គការសហប្រជាជាតិ ។ ការចរចានេះមានរយៈពេលយូរ ហើយជាការពិត មានការខ្វែងយោបល់គ្នា និងយល់ច្រឡំច្រើនលើកច្រើនសារ ទំរាំតែភាគីទាំងពីរឯកភាពគ្នានៅឆ្នាំ ២០០៣ លើខ្លឹមសារលំអិតនៃការចូលរួមរបស់សហគមន៍អន្តរជាតិ ។



ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

កងទ័ពខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥



រូបភាពដោយ៖ ដឹរ ពិសី

សិស្សានុសិស្សទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅទីក្រុងភ្នំពេញ ដើម្បីយល់ដឹងអំពីអំពើឃោរឃៅដែលបានកើតឡើងក្នុងរបបខ្មែរក្រហម



រូបភាពដោយៈ ឆ សុគន្ធា

ការអុជធូបឧទ្ទិសកុសលជូនព្រលឹងជនរងគ្រោះនៃរបបខ្មែរក្រហម នៅបូជនីយដ្ឋានជើងឯក

អង្គជំនុំជម្រះវិសាមញ្ញត្រូវបង្កើតឡើង ដើម្បីធ្វើការកាត់សេចក្ដីជាសាធារណៈ និងប្រកបដោយយុត្តិធម៌សមស្របទៅនឹងបទដ្ឋានស្តង់ដារអន្តរជាតិ ។ គោលដៅសំខាន់នៃតុលាការនេះ គឺផ្ដល់យុត្តិធម៌ជូនប្រជាជនកម្ពុជា ទាំងអ្នកដែលបាត់បង់ជីវិត និងអ្នកដែលនៅរស់ ។ មានការរំពឹងទុកថា ការកាត់សេចក្ដីដែលប្រកបដោយយុត្តិធម៌នេះ នឹងជួយធ្វើអោយអ្នកដែលនៅរស់ពីការសំលាប់រង្គាល បានធូរស្បើយពីរបួសអតីតកាល ។ ការកាត់ក្ដីនេះ ក៏មានប្រយោជន៍ផងដែរ សំរាប់មនុស្សជំនាន់ក្រោយ គឺអប់រំកុលបុត្រកុលធីតាកម្ពុជា អោយយល់ដឹងពីទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃប្រទេសរបស់យើង ។

# សំណួរទី ២

## ហេតុអ្វីបានជាយើងធ្វើការកាត់ក្ដីក្នុងពេលឆាប់ៗនេះ? តើការកាត់ក្ដីខ្មែរក្រហមនេះនឹងផ្ដល់ផលប្រយោជន៍យ៉ាងដូចម្ដេចចំពោះប្រជាជនកម្ពុជា ?

អស់រយៈពេលជាង ២៧ ឆ្នាំ កន្លងមកហើយ ដែលប្រជាជនកម្ពុជាបានរង់ចាំយុត្តិធម៌ ។ ចុងបញ្ចប់ ពេលវេលាបានមកដល់ហើយ សំរាប់អោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ ដែលខ្លួនបានប្រព្រឹត្តក្នុងសម័យនោះ និងដើម្បីអោយមានយុត្តិធម៌នៅក្នុងកំណត់ហេតុនៃប្រវត្តិសាស្ត្រ ។



រូបភាពដោយៈ ជី ពិសី

ព្រះសង្ឃធ្វើការសូត្រធម៌

តាមរយៈនៃការធ្វើការវិនិច្ឆ័យឧក្រិដ្ឋជននៅក្នុងតុលាការជាសាធារណៈ និងប្រកបដោយយុត្តិធម៌ ព្រមទាំងការដាក់ទណ្ឌកម្មជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះ ការជំនុំជម្រះនេះនឹងជួយពង្រឹងនីតិរដ្ឋរបស់យើង ព្រមទាំងជាគំរូមួយដល់ជនទាំងឡាយណា ដែលមិនគោរពច្បាប់នៅកម្ពុជា និងសំរាប់របបឃោរឃៅនៅទូទាំងពិភពលោក ។ ប្រសិនបើឧក្រិដ្ឋជនដឹងថា ពួកគេនឹងទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ពួកគេប្រហែលជាញញើតនឹងប្រព្រឹត្តបទឧក្រិដ្ឋ ។ ដោយគាំទ្រ និងរៀនសូត្រអំពីយុត្តិធម៌ យើងទាំងអស់គ្នាអាចរួមវិភាគទានក្នុងការស្តារសង្គមជាតិយើងឡើងវិញ ។

## សំណួរទី ៣ | តើអ្នកណាខ្លះ នឹងត្រូវនាំយកមកធ្វើការកាត់ក្តី ?

ក្នុងស្មារតីចង់បានយុត្តិធម៌ ការពិត និងការផ្សះផ្សាជាតិ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានឯកភាពគ្នាថា អង្គជំនុំជម្រះវិសាមញ្ញនេះ គប្បីកំរិតការកាត់ទោសចំពោះតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានរៀបចំផែនការ ឬចេញបទបញ្ជា និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរទាំងនោះ ។ ដូច្នេះ គេរំពឹងថា មានតែជនមួយចំនួនតូចតែប៉ុណ្ណោះ ដែលត្រូវនាំយកមកធ្វើការកាត់សេចក្តី ។

ប៉ុន្មានឆ្នាំកន្លងមកនេះ កងទ័ពរបស់ខ្មែរក្រហមរាប់ម៉ឺននាក់បានចុះចូលជាមួយរាជរដ្ឋាភិបាល ។ ពួកគេគ្មានអ្វីដែលត្រូវភ័យខ្លាចពីតុលាការ



រូបភាពដោយៈ ធ្វី ហ្គ្រេស

ទាហានខ្មែរក្រហមដាក់អាវុធចុះចូលជាមួយកងទ័ពរាជរដ្ឋាភិបាល

នេះទេ ។ គោលនយោបាយផ្សះផ្សាជាតិស្ថិតនៅជាធរមាននៅឡើយ ។ សូមចងចាំថា មានតែជនដែលប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរតែប៉ុណ្ណោះ ដែលត្រូវធ្វើការកាត់ក្តីនៅក្រោមច្បាប់ ដែលមានចែងនៅក្នុងសាលាក្តីពិសេសនេះ ។

តុលាការវិសាមញ្ញនេះ នឹងមានការទទួលខុសត្រូវក្នុងការសំរេចចិត្តថា តើខ្មែរក្រហមមួយណាជា "មេដឹកនាំជាន់ខ្ពស់ ហើយអ្នកណាដែលជាអ្នកទទួលខុសត្រូវខ្ពស់" ជាងគេក្នុងបទឧក្រិដ្ឋពេលនោះ ។ តុលាការនឹងស្វែងរកតែមុខសញ្ញាទាំងនោះ គឺមិនមែនស្វែងរកគ្រប់អតីតសមាជិកខ្មែរក្រហម

ឬមនុស្សម្នានៅក្នុងបណ្តាភូមិផ្សេងៗទូទាំងកម្ពុជា ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមកាន់កាប់អំណាចនោះទេ ។

- សមាជិកខ្មែរក្រហមដែលមានបណ្តាស័ក្តិទាប ឬមធ្យមដែលមិនមានការទទួលខុសត្រូវខ្ពស់ជាងគេក្នុងបទឧក្រិដ្ឋធ្ងន់ធ្ងរទាំងនោះ នឹងមិនត្រូវយកមកកាត់ទោសទេ ។ ពួកគេភាគច្រើន ឥឡូវនេះបានចូលរួមនៅក្នុងសង្គមឡើងវិញហើយ ។ យើងសង្ឃឹមថា អ្នកទាំងនោះនឹងរស់នៅដោយសុខសាន្តតាមគោលការណ៍ពុទ្ធសាសនា និងជួយសហការអភិវឌ្ឍន៍ប្រទេសជាតិ ។
- កូន ឬសមាជិកគ្រួសារផ្សេងៗទៀត ឬអ្នកធ្លាប់រាប់អានមេដឹកនាំខ្មែរក្រហម នឹងមិនទទួលខុសត្រូវលើបទឧក្រិដ្ឋជំនួសឪពុកម្តាយ ឬសហគមន៍របស់ខ្លួនទេ ។
- អ្នកដែលបានស្លាប់បាត់បង់ជីវិតទៅ នឹងមិនត្រូវធ្វើការកាត់ទោសឡើយ ។ តុលាការកាត់ក្តីតែអ្នកនៅរស់ទេ ។

## សំណួរទី ៤ | តើជនសង្ស័យនឹងទទួលនូវការដាក់ទោសអ្វីខ្លះ ប្រសិនបើគេត្រូវបានកាត់ក្តីថា មានទោស ?

ទោសអតិបរមា គឺការដាក់ទោសអស់មួយជីវិត ហើយការដាក់ទោសអប្បរមា គឺការដាក់គុករយៈពេល ៥ ឆ្នាំ ។ គ្មានការកាត់ទោសប្រហារជីវិតទេ ។ ការកាត់ទោសប្រហារជីវិត គឺខុសនឹងច្បាប់រដ្ឋធម្មនុញ្ញនៅកម្ពុជា ។

បន្ថែមពីលើនេះ តុលាការអាចបញ្ជាអោយធ្វើការរឹបអូសទ្រព្យសម្បត្តិ ឬថវិកា ដែលចុងចោទទទួលបានមិនស្របច្បាប់ ឬដោយការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ។ ទ្រព្យសម្បត្តិដែលបានរឹបអូសនេះនឹងត្រូវប្រគល់ជូនទៅរដ្ឋ ។

## សំណួរទី ៥ | តើមានការលើកលែងទោស ឬការអនុគ្រោះទោសដែរ ឬទេ ?

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសរួចជាស្រេចហើយនៅក្នុងច្បាប់និងកិច្ចព្រមព្រៀងថា នឹងមិនស្នើសុំការលើកលែងទោស ឬការអនុគ្រោះទោសសំរាប់ជនណាម្នាក់ ដែលត្រូវទទួលធ្វើការស៊ើបអង្កេត ឬត្រូវបានកាត់សេចក្តីថាមានទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញទេ ។

## សំណួរទី ៦ | តើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាខ្លះដែលត្រូវបានធ្វើការកាត់ក្តីរួចហើយ ?

នៅឆ្នាំ ១៩៧៩ មានការកាត់ក្តីអំពើប្រល័យពូជសាសន៍នៅទីក្រុងភ្នំពេញ ដែលគេស្គាល់ថា ជាតុលាការប្រជាជនបដិវត្តន៍ ។ តុលាការនេះបានកាត់ទោស អៀង សារី និង ប៉ុល ពត ហើយបានរកឃើញថា ពួកគេទាំងពីរជាប់ពិរុទ្ធខាងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប៉ុន្តែអ្នកទាំងពីរមិនមានវត្តមាននៅចំពោះមុខតុលាការទេ ហើយក៏មិនបានទទួលទោសពីកំហុសដែលខ្លួនបានប្រព្រឹត្តនោះដែរ ។

នៅឆ្នាំ ១៩៩៦ ព្រះមហាក្សត្រនាពេលនោះ បានប្រទានការអនុគ្រោះទោសចំពោះ អៀង សារី ដែលបានទទួលសាលក្រមប្រកាសដាក់ទោស ដោយតុលាការប្រជាជនបដិវត្តន៍បានកាត់ទោសគាត់ពីបទប្រល័យពូជសាសន៍ ។ វាអាស្រ័យទៅលើចៅក្រមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការសំរេចទៅលើវិសាលភាពនៃការអនុគ្រោះទោសនេះ ។ ប្រសិនបើ អៀង សារី មិនអាចកាត់ទោសឡើងវិញពីបទប្រល័យពូជសាសន៍ក៏ដោយ ក៏អាចមានបទចោទប្រកាន់ផ្សេងៗទៀត ដែលគេអាចលើកឡើងប្រឆាំងនឹងគាត់ ។ វាអាស្រ័យទៅលើភស្តុតាងដែលគេអាចរកបាន ។

នៅឆ្នាំ ១៩៩៧ ពួកខ្មែរក្រហមខ្លួនឯងផ្ទាល់ បានកាត់ទោស ប៉ុល ពត ពីបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្តនៅក្នុងវង្វង់អង្គការរបស់គាត់ក្រោយឆ្នាំ ១៩៧៩ ។ ប៉ុល ពត ស្លាប់នៅឆ្នាំ ១៩៩៨ ។ ដូច្នេះ អង្គជំនុំជម្រះវិសាមញ្ញមិនអាចកាត់សេចក្តីគាត់បានទេ ។



រូបភាពដោយ៖ សារព័ត៌មានខ្មែរ អេសប៉េក

ការបើកសម័យប្រជុំនៃតុលាការប្រជាជនបដិវត្តន៍ នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៩



រូបភាពដោយ៖ ពជ សម្បត្តិ

អគារតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## សំណួរទី ៧

**ចុះចំពោះបណ្តាប្រទេសដែលធ្លាប់បានគាំទ្រ ឬក៏ជាប់ពាក់ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យ ឬក៏បណ្តាប្រទេសដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមនៅកម្ពុជាមុនឆ្នាំ ១៩៧៥ តើប្រទេសទាំងនោះត្រូវឡើងតុលាការដែរ ឬអត់ ?**

*អត់ទេ ។ អង្គជំនុំជម្រះវិសាមញ្ញ អាចកាត់ក្តីតែបុគ្គលណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ ។ តុលាការនេះ មិនអាចកាត់ក្តីប្រទេស ឬអង្គការណាបានឡើយ ។*

## សំណួរទី ៨

**ចុះចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ឬអ្នកដទៃទៀត ក្រោយឆ្នាំ ១៩៧៩ ?**

*អត់ទេ ។ អំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញមានព្រំដែន ។ តុលាការនេះអាចកាត់សេចក្តីតែឧក្រិដ្ឋកម្មណា ដែលបានប្រព្រឹត្តនៅកម្ពុជា ក្នុងចន្លោះថ្ងៃទី ១៧ មេសា ១៩៧៥ រហូតដល់ថ្ងៃទី ៦ មករា ១៩៧៩ តែប៉ុណ្ណោះ ។*

*ទោះជាយ៉ាងនេះក្តី តុលាការកម្ពុជាបច្ចុប្បន្ន មានអំណាចនឹងកាត់សេចក្តីលើឧក្រិដ្ឋកម្មផ្សេងទៀត ។ ឧទាហរណ៍ ការកាត់ក្តីទាយទាហានខ្មែរក្រហមដែលទទួលខុសត្រូវពីបទពួនស្ទាក់វាយប្រហាររថភ្លើងពីភ្នំពេញ ទៅខេត្តកំពត*



ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា

*ការវិលត្រឡប់ចូលទីក្រុងភ្នំពេញវិញនៅឆ្នាំ ១៩៧៩*

## រូបគំនូរបង្ហាញពីសាលសវនាការ



ដោយៈ យ៉ូសេ អេនស៊ីណាស

នៅឆ្នាំ ១៩៩៨ ដែលបានសំលាប់ប្រជាជនកម្ពុជា ១១ នាក់ និងសំលាប់ចំណាប់ខ្មាំងបស្ចឹមប្រទេសបីនាក់ បានប្រព្រឹត្តទៅនៅក្នុងតុលាការសាមញ្ញបុធម្មតា ។ ក្នុងករណីនេះ អតីតឧត្តមសេនីយ៍ខ្មែរក្រហម ឈ្មោះ សំ ប៊ិត និង នួន ប៉ែត និងវរសេនីយ៍ឯក ឈូក រិន ត្រូវបានតុលាការរកឃើញថា ជាប់ពិរុទ្ធ ។

## សំណួរទី ៩ | តើការកាត់ក្តីនឹងចាប់ផ្តើមនៅពេលណា ?

ការជំនុំជម្រះលើកដំបូងអាចសង្ឃឹមថាចាប់ផ្តើមនៅឆ្នាំ ២០០៧ ។ ចៅក្រម និងព្រះរាជអាជ្ញាទាំងឡាយ ត្រូវបានតែងតាំងនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០០៦ ហើយការចោទប្រកាន់ និងការស៊ើបអង្កេតនឹងចាប់ផ្តើមក្នុងពេលឆាប់នេះៗ ។

ទាំងរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ គឺដឹងអំពីភាពបន្ទាន់នៃការបង្កើតការជនុំជម្រះក្តីនេះ ហើយកំពុងធ្វើការយ៉ាងសកម្ម ដើម្បីធ្វើការងារនេះអោយបានឆាប់ ។ មន្ត្រីជាន់ខ្ពស់ផ្នែករដ្ឋាបាលទាំងឡាយត្រូវបានតែងតាំងនៅចុងឆ្នាំ ២០០៥ ។ ឯកឧត្តម ស៊ាន វិសុទ្ធ បានតែងតាំងជាប្រធានការិយាល័យរដ្ឋាបាល និងអ្នកស្រី មីសែល លី អនុប្រធាន ។ នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ទាំងបុគ្គលិកជាតិ និងអន្តរជាតិ បានចូលទៅធ្វើការក្នុងទីតាំងនៃអង្គជំនុំជម្រះវិសាមញ្ញ ។

## សំណួរទី ១០ | តើការកាត់ក្តីនឹងប្រើរយៈពេលប៉ុន្មានឆ្នាំ ?

ដំណើរការកាត់ក្តីនេះអាចមានរយៈពេល ៣ ឆ្នាំ ទោះបីជាយ៉ាងណាក៏ដោយ ក៏មិនមាននរណាម្នាក់អាចប៉ាន់ប្រមាណទុកអោយបានពិតប្រាកដថា តើសាលាក្តីនេះនឹងប្រើរយៈពេលប៉ុន្មានឆ្នាំ ។ វាអាស្រ័យថា តើអ្នកស៊ើបអង្កេតត្រូវការរយៈពេលប៉ុន្មាន ដើម្បីប្រមែប្រមូលភស្តុតាង តើមានមនុស្សប៉ុន្មាននាក់នឹងត្រូវយកមកកាត់ទោស តើមានសាក្សីប៉ុន្មាននាក់នឹងត្រូវអញ្ជើញមកបំភ្លឺនៅតុលាការ ហើយថាតើនឹងមានការប្តឹងឧទ្ធរណ៍ប៉ុន្មានករណី ។ នៅពេលដែលការជនុំជម្រះ និងការប្តឹងឧទ្ធរណ៍បានចប់សព្វគ្រប់អង្គជំនុំជម្រះវិសាមញ្ញក៏នឹងត្រូវរំលាយខ្លួនជាស្វ័យប្រវត្តិ ។

## សំណួរទី ១១ | តើការកាត់ក្តីនេះនឹងត្រូវប្រព្រឹត្តទៅនៅកន្លែងណា ?

ការកាត់ក្តីនេះ នឹងប្រព្រឹត្តទៅនៅសាលតុលាការដ៏ធំមួយដែលស្ថិតនៅជាយក្រុងនៅភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ ៤ ភូមិអង្គ ឃុំកន្ទោក ស្រុកអង្គស្នួល ។

# សំណួរទី ១២ | តើអង្គជំនុំជម្រះវិសាមញ្ញធ្វើការរបៀបដូចម្តេច ?

តុលាការវិសាមញ្ញនេះ បែកចេញជាពីរកម្រិត ឬពីរថ្នាក់ ៖ គឺសាលាដំបូង និងតុលាការកំពូល ។ សំរាប់សាលាដំបូង មានចៅក្រមចំនួន ៥ រូប គឺចៅក្រមកម្ពុជា ៣ រូប និងចៅក្រមអន្តរជាតិ ២ រូប ។ សំរាប់តុលាការកំពូល មានចៅក្រម ៧ រូប គឺចៅក្រមកម្ពុជា ៤ រូប និងចៅក្រមអន្តរជាតិ ៣ រូប ។

នៅក្រោមច្បាប់កម្ពុជាសព្វថ្ងៃនេះ ក៏ដូចជានៅក្នុងបណ្តាប្រទេសផ្សេងទៀតដែរ គឺគ្មានគណៈវិនិច្ឆ័យ ឬគណៈទីប្រឹក្សាប្រជាជនទេ ។ រាល់ការសំរេចចិត្តទាំងអស់ គឺធ្វើឡើងដោយអង្គចៅក្រម ។

**តុលាការកំពូល៖ ចៅក្រម ៧ រូប**
**កម្ពុជា ៤ អន្តរជាតិ ៣**

↑

*ការប្តឹងឧទ្ធរណ៍ឡើងតុលាការកំពូល*

**សាលាដំបូង៖ ចៅក្រម ៥ រូប**
**កម្ពុជា ៣ អន្តរជាតិ ២**



រូបភាពទាំងអស់នេះបង្ហាញពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាសាមញ្ញ
ការកាត់សេចក្តី គឺសំរាប់ផលប្រ

។ ប្រជាជនគ្រប់រូបមានសិទ្ធ ដើម្បីចូលរួមស្តាប់អង្គជំនុំជម្រះវិសាមញ្ញ ។
យោជន៍របស់ប្រជាជនកម្ពុជា ។



ប្រសិនបើរូបភាពទាំងអស់គ្មានការបញ្ជាក់ផ្សេងទេ រូបភាពទាំងអស់នោះ ថតដោយ ជីវ ពិសី

# សំណួរទី ១៣ | តើអ្នកណាអាចចូលទៅស្តាប់ការកាត់ក្តីបាន ?

អ្នកណាក៏បាន ។ ការកាត់សេចក្តីនេះ គឺសំរាប់ប្រជាជនកម្ពុជា អ្នកណាក៏អាចចូលទៅស្តាប់ការកាត់ក្តីនេះបានដែរ មិនថា ចាស់ ឬក្មេងមាន ឬក្រ ប្រជាជននៅទីក្រុង ឬនៅជនបទឡើយ ។ ម្យ៉ាងទៀត ជនបរទេសក៏អាចចូលរួមបានដែរ ។ គ្មានការបង់ប្រាក់ចូលទេ ហើយផ្នែកមួយនៃសាលសវនាការនឹងត្រូវបំរុងទុកសំរាប់សាធារណជនទូទៅ ជាពិសេសសំរាប់ជនទាំងឡាយណា ដែលមានការទំនាក់ទំនងពិសេសទៅលើករណីជាក់លាក់ណាមួយ ។

ការកាត់ក្តីនេះ នឹងបើកចំហជូនសាធារណជនគ្រប់ពេលវេលា លើកលែងតែក្នុងស្ថានការណ៍ពិសេសនៅពេលដែលចៅក្រមសំរេចថា ត្រូវហាមឃាត់មិនអោយមានវត្តមានសាធារណជន ដើម្បីការពារអត្តសញ្ញាណរបស់សាក្សី ឬជនរងគ្រោះ ។ យើងរំពឹងថា ដំណើរការកាត់សេចក្តីនឹងមានធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍នៅខាងក្រៅបន្ទប់សវនាការ ប្រសិនបើមនុស្សដែលចង់ចូលស្តាប់មានគ្នាច្រើនលើសលប់ជាងចំនួនមនុស្សដែលអាចផ្ទុកបាននៅក្នុងបន្ទប់កាត់ក្តី ។

# រូបគំនូរបង្ហាញពីអង្គជំនុំជម្រះក្តីដែលកំពុងប្រព្រឹត្តឡើង




ចៅក្រម ៤ រូប ក្នុងចំណោមចៅក្រម ៥ រូប ត្រូវបោះឆ្នោតដើម្បីធ្វើការសំរេចចិត្ត ។ តាមនីតិវិធីនេះ ទាំងចៅក្រមជាតិ និងអន្តរជាតិ មិនអាចធ្វើការសំរេចចិត្តតែឯងបានឡើយ ។

ដោយ : ឃុំ សេ អេងស៊ុនការ

## សំណួរទី ១៤ | ប្រសិនបើយើងមិនអាចទៅបាន តើធ្វើដូចម្តេចយើងអាចដឹងបានពីអ្វីដែលកំពុងកើតឡើងនៅក្នុងតុលាការ ?

សាធារណជនទូទាំងសាកលលោកនឹងចង់ដឹងចង់ឮសកម្មភាព ឬព័ត៌មាន ដែលកំពុងកើតឡើងនៅក្នុងពេលសវនាការជម្រះក្តី ។ លោកអ្នកអាចនឹងតាមដានព្រឹត្តិការណ៍ទាំងនោះបានតាមបណ្តាញវិទ្យុ និងទូរទស្សន៍ក្នុងស្រុក និងអន្តរជាតិ និងនៅក្នុងកាសែត ទស្សនាវដ្តីផ្សេងៗ ។ ជាមួយគ្នានេះដែរ ក្រុមកិច្ចការសារធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញកំពុងរៀបចំចែកចាយព័ត៌មានអំពីតុលាការនេះទូទាំងប្រទេសកម្ពុជា ។ ចុងបញ្ចប់ អង្គការក្រៅរដ្ឋាភិបាលនឹងមានកម្មវិធីផ្សព្វផ្សាយ ក្នុងគោលបំណងជួយអោយជនកម្ពុជា យល់ដឹងអំពីនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## សំណួរទី ១៥ | តើចៅក្រមត្រូវតែងតាំងឡើងយ៉ាងដូចម្តេច ?

ចៅក្រមអន្តរជាតិមួយចំនួន ត្រូវបានជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នៅថ្ងៃទី៤ ឧសភា ២០០៦ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជា បានជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិចំនួន ១២ រូប ដែលអញ្ជើញមកមកពីប្រទេស ១០ ផ្សេងៗគ្នា ។ ជាមួយនោះផងដែរ អង្គការច្បាប់កំពូលក៏បានជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញាកម្ពុជាចំនួន ១៧ រូបផងដែរ ។ ចៅក្រម និងព្រះរាជអាជ្ញាទាំង ២៩ រូបនេះ បានត្រូវបានតែងតាំងដោយព្រះរាជក្រិតនៅថ្ងៃ ៧ ឧសភា ២០០៦ ។ ពួកគេត្រូវតែស្មោះត្រង់ និងឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ។ ពួកគេមិនត្រូវទទួលការបង្គាប់បញ្ជាពីជនណាមួយរដ្ឋាភិបាល ឬពីប្រភពណាមួយផ្សេងទៀតឡើយ ។ ចៅក្រមទាំងអស់នឹងទទួលការហ្វឹកហ្វឺនជាក់លាក់ ។ ចៅក្រមបរទេសនឹងរៀនសូត្រពីច្បាប់កម្ពុជា ហើយចៅក្រមកម្ពុជានឹងរៀនសូត្រពីច្បាប់អន្តរជាតិ ។

## សំណួរទី ១៦ | តើអង្គចៅក្រមនឹងឈានដល់ការចេញសេចក្តីសំរេចឯកច្ឆន្ទយ៉ាងដូចម្តេច ?

នៅក្នុងដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ចៅក្រមទាំងអស់នឹងព្យាយាមសំរេចអោយបាននូវការព្រមព្រៀងគ្នាជាឯកច្ឆន្ទទៅលើរាល់ការសំរេច ឬសាលក្រមណាមួយដែលបានធ្វើឡើង ។ ប្រសិនបើចៅក្រមមិនយល់ព្រមទាំងស្រុងនោះទេ សេចក្តីសំរេចនឹងតំរូវធ្វើតាមអ្វីដែលហៅថា “ភាគច្រើនលើសលប់” ។

នៅក្នុងសាលាដំបូង ចៅក្រម ៤ នាក់ ក្នុងចំណោមចៅក្រម ៥ នាក់ ត្រូវតែបោះឆ្នោតយល់ព្រម សំរាប់ការកាត់សេចក្តីអោយជាប់ទោស ហើយនៅក្នុងតុលាការកំពូល ចៅក្រម ៥ នាក់ ក្នុងចំណោមចៅក្រម ៧ នាក់ ត្រូវតែបោះឆ្នោតយល់ព្រមសំរាប់ការកាត់សេចក្តីសំរេច ឬសាលដីកាសាលាឧទ្ធរណ៍ ។ ដូច្នេះរាល់សេចក្តីសំរេច ត្រូវតែមានការគាំទ្រពីចៅក្រមកម្ពុជាផង និងចៅក្រមអន្តរជាតិផង ។

ដោយផ្អែកតាមរូបមន្តនេះ ប្រសិនបើសំឡេង “ភាគច្រើនលើសលប់” មិនអាចឈោងចាប់បានទេ នោះចុងចោទនឹងត្រូវដោះលែង ។ នេះ គឺអនុលោមទៅតាមគោលការណ៍មូលដ្ឋានគ្រឹះនៃច្បាប់ដែលចែងថា អ្នកណាក៏ដោយត្រូវបានចាត់ទុកថាគ្មានទោស រហូតទាល់តែអ្នកនោះ ត្រូវបានកាត់ទោស ហើយរកឃើញកំហុសពីបទឧក្រិដ្ឋណាមួយ ។

## សំណួរទី ១៧

**តើអ្នកណាជាអ្នកសំរេចថា តើអ្នកណាខ្លះនឹងត្រូវកាត់សេចក្តី ? តើអ្នកណាជាអ្នកសំរេចថា តើពួកគេនឹងត្រូវចោទប្រកាន់ពីបទល្មើសអ្វី ?**

អង្គជំនុំជម្រះវិសាមញ្ញនឹងមានសហព្រះរាជអាជ្ញាពីររូប (កម្ពុជាមួយរូប និងអន្តរជាតិមួយរូប) នឹងប្រមូលភស្តុតាង ហើយសំរេចថាអ្នកណាមួយនឹងទទួលរងការចោទប្រកាន់ពីបទឧក្រិដ្ឋអ្វីនោះ ។ បន្ទាប់មកសហព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងក្តីទៅជូនចៅក្រមស៊ើបអង្កេតពីររូប (កម្ពុជាមួយរូប និងអន្តរជាតិមួយរូប) ។ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ហើយករណីនោះនឹងបញ្ជូនទៅធ្វើការកាត់សេចក្តី (ភស្តុតាងជាច្រើនត្រូវបានគេប្រមូលទុករួចហើយ និងកំពុងរក្សាទុកដោយសុវត្ថិភាព) ។

## សំណួរទី ១៨

**តើមានអ្វីកើតឡើង ប្រសិនបើសហព្រះរាជអាជ្ញា ឬក៏សហចៅក្រមស៊ើបអង្កេតមិនយល់ស្របគ្នាថា តើត្រូវបញ្ជូនរឿងក្តីណាមួយទៅធ្វើការកាត់សេចក្តី ឬក៏អត់ ?**

ទាំងសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត នឹងព្យាយាមសំរេចអោយបាននូវការព្រមព្រៀងគ្នា ប៉ុន្តែប្រសិនបើពួកគេមិនអាចឈានដល់ការឯកភាពគ្នានោះទេ ពេលនោះចៅក្រម ៥ រូប មកពីអង្គបុរេជំនុំជម្រះនឹងជួបជុំគ្នាធ្វើការ ថាតើត្រូវបញ្ជូនរឿងក្តីទៅកាត់សេចក្តី ឬក៏អត់ ? ទាំងសហព្រះរាជអាជ្ញា ទាំងចៅក្រមកម្ពុជា និងអន្តរជាតិ ទាំងសហចៅក្រមស៊ើបអង្កេត មិនអាចធ្វើអោយរាំងស្ទះដល់ការបញ្ជូនរឿងក្តីណាមួយទៅធ្វើការកាត់សេចក្តីនោះទេ ។

## សំណួរទី ១៩

**តើចៅក្រមនៅសាលាដំបូងធ្វើការងារអ្វីខ្លះ ?**

ចៅក្រមនៅសាលាដំបូងនឹងពិនិត្យភស្តុតាងដែលលើកឡើងដោយព្រះរាជអាជ្ញា និងមេធាវីចុងចោទ ។ បន្ទាប់មក ចៅក្រមនឹងពិចារណាលើសេចក្តីថ្លែងការណ៍ទាំងសងខាង រួចធ្វើការពិភាក្សាសំរេចចិត្តថា តើជនសង្ស័យមានជាប់ពិរុទ្ធ ឬក៏អត់ ។ ចៅក្រមកាត់ក្តីត្រូវចេញនូវសេចក្តី

វិនិច្ឆ័យ ឬសាលក្រមមួយជាលាយលក្ខណ៍អក្សរពន្យល់ពីហេតុផលនៃការវិនិច្ឆ័យដែលបានធ្វើឡើង ។ ប្រសិនបើមានចៅក្រមណាម្នាក់មិនឯកភាពនឹងសាលក្រមនោះទេ ចៅក្រមមានតួនាទីពន្យល់អំពីហេតុផលដែលនាំអោយខ្លួនបោះឆ្នោតផ្សេងពីមតិភាគច្រើន ។ រាល់ការវិនិច្ឆ័យ ឬសាលក្រមទាំងអស់ត្រូវធ្វើឡើងជាសាធារណៈ ។



វិចិត្ររូបខាងលើនេះ តំណាងអោយយុត្តិធម៌សម័យអង្គរ ត្រូវបានយកមកប្រើក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ វាជារូបភាពដែលតាំងនៅជញ្ជាំងក្នុងសាលាឧទ្ធរណ៍នៃក្រសួងយុត្តិធម៌

## បដិរូប និងត្រាជាផ្លូវការសំរាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បដិរូប តំណាងអោយអង្គជំនុំជម្រះវិសាមញ្ញ ដោយមានការពណ៌នារួមមួយនូវការគ្រប់គ្រងនៃតុលាការកម្ពុជាក្នុងសម័យបុរាណអង្គរ និងអមក្បួរផ្លែអូលីវ ជាសញ្ញារបស់អង្គការសហប្រជាជាតិ ដែលតំណាងអោយសន្តិភាព។ ពណ៌ជាផ្លូវការ គឺខៀវចាស់។

រូបនេះអង្គុយលើក្រណាត់តេអ៊ី ហើយកាន់ដាវមួយ ដើម្បីតំណាងអោយអំណាចតុលាការ។ វា គឺជារូបតាំងលើជញ្ជាំងកណ្តាលគេ នៅកន្លែងអតីតតុលាការឧទ្ធរណ៍ក្នុងក្រសួងយុត្តិធម៌នៅទីក្រុងភ្នំពេញ។ រូបនោះ អមដោយអ្នកជំនួយការពីរនាក់ដែលកំពុងអះអាងច្បាប់ ដែលបានចារដោយដៃលើស្លឹករឹត។

ត្រាជាផ្លូវការបង្ហាញពីបដិរូបព័ទ្ធដោយរង្វង់ពីរដែលសរសេរឈ្មោះពេញជាអក្សរខ្មែរ "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា " និងអក្សរកាត់ជាភាសាអង់គ្លេស ECCC, (Extraordinary Chambers in the Courts of Cambodia) ជាភាសាបារាំង CETC (Chambres extraordinaries au sein des Tribunaux Cambodgiens)

## សំណួរទី ២០ | តើភស្តុតាងអ្វីខ្លះ នឹងត្រូវប្រើប្រាស់នៅពេលកាត់ក្តី ?

ភស្តុតាងនឹងត្រូវបង្ហាញជូនដោយព្រះរាជអាជ្ញាផង និងមេធាវីចុងចោទផង ហើយភស្តុតាងទាំងនេះអាចជា ៖

- ឯកសារ
- ភស្តុតាងតាមរយៈរូបរាងកាយ ដូចជា រណ្តៅសពរួម ឬក៏អតីតគុក
- សេចក្តីថ្លែងការណ៍របស់សាក្សី ឬរបស់

ជនជាប់ចោទកាលពីប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ឯកសាររាប់ពាន់សន្លឹកត្រូវបានប្រមូលចងក្រងទុក ហើយរណ្តៅសពរួម គុក និងបូជនីយដ្ឋានរាប់រយកន្លែង ត្រូវបានគេទៅពិនិត្យមើល និងគូរជាផែនទីដោយគណៈកម្មាធិការស្រាវជ្រាវរបស់រណសិរ្ស មជ្ឈមណ្ឌលឯកសារកម្ពុជា និងដោយកម្មវិធីស្រាវជ្រាវអំពីការប្រល័យពូជសាសន៍នៅកម្ពុជា ។ ភស្តុតាងទាំងអស់នោះនឹងផ្តល់ជូនដល់អង្គជំនុំជម្រះវិសាមញ្ញ ។

នៅក្នុងតុលាការកម្ពុជា គ្រប់ភស្តុតាងទាំងអស់ដែលគេប្រមូលបានដោយត្រឹមត្រូវតាមនីតិវិធីអាចយកមកពិចារណាបាន ។ វាអាស្រ័យទៅលើចៅក្រមជាអ្នកសំរេច ។

## សំណួរទី ២១ | តើតុលាការនឹងធ្វើការកាត់ក្តីអំពីបទឧក្រិដ្ឋអ្វី ? តើការកាត់ក្តីប្រើច្បាប់កម្ពុជា ឬក៏ច្បាប់អន្តរជាតិ ?

នៅក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ គេប៉ាន់ស្មានថា មានមនុស្សប្រមាណជាង ៣ លាននាក់ ដែលបានស្លាប់ពីការធ្វើទារុណកម្ម ការប្រហារជីវិត ការអត់ឃ្លាន និងជម្ងឺដែលមិនមានការព្យាបាល ។ ការស្លាប់ទាំងនេះអាចត្រូវគេបង្ហាញអោយឃើញនៅចំពោះមុខតុលាការថា វា គឺជាការទទួលខុសត្រូវផ្ទាល់របស់អ្នកគ្រប់គ្រងប្រទេសនាពេលនោះ ។

ចៅក្រមចាំបាច់នឹងធ្វើការសំរេចចិត្តអោយបានច្បាស់លាស់អំពីបទឧក្រិដ្ឋអ្វី ដែលត្រូវបានប្រព្រឹត្តនៅពេលនោះ និងដោយអ្នកណាខ្លះ ។ ភស្តុតាងលើសលប់ស្តីពីបទឧក្រិដ្ឋសាហាវឃោរឃៅ ត្រូវបានគេប្រមូលចងក្រងឡើងជាងពីរទសវត្សរ៍កន្លងមកនេះ ។ ការប្រឈមមុខសំរាប់ធ្វើការកាត់សេចក្តីនេះ នឹងអាស្រ័យទៅលើការប្រមែប្រមូលភស្តុតាងអោយបានគ្រប់គ្រាន់ ដើម្បីរំលេចឡើងអោយឃើញនូវទោសកំហុសរបស់បុគ្គលណាមួយដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ។ ជនសង្ស័យអាចទទួលការចោទប្រកាន់នូវបទឧក្រិដ្ឋ ដូចតទៅ ៖

| | |
|---|---|
| **នៅក្រោមច្បាប់របស់កម្ពុជា រួមមាន៖** | ▪ អំពើមនុស្សឃាដ<br>▪ ការធ្វើទារុណកម្ម<br>▪ ការធ្វើទុក្ខបុកម្នេញខាងសាសនា |
| **នៅក្រោមច្បាប់របស់អន្តរជាតិ រួមមាន៖** | ▪ **អំពើប្រល័យពូជសាសន៍**<br>ការសំលាប់ ឬធ្វើអោយខូចខាត បាត់បង់ដោយចេតនា បំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ។<br>▪ **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**<br>ដូចជា អំពើមនុស្សឃាដ ការសំលាប់អោយផុតពូជ ការធ្វើទាសភាព ការនិរទេស ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ និងបទឧក្រិដ្ឋផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ ។<br>▪ **ឧក្រិដ្ឋកម្មសង្គ្រាម**<br>ដូចជា ការគ្រប់គ្រងអសីលធ៌ទៅលើជនស៊ីវិល ឬអ្នកទោសសង្គ្រាម និងវិធីសាស្ត្រមិនស្របច្បាប់ក្នុងការធ្វើសង្គ្រាម ។<br>▪ **ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌**<br>ដូចជា ការលួច ឬបំផ្លិចបំផ្លាញអាគារប្រវត្តិសាស្ត្រ ទីតាំងបុរាណវិទ្យា សារមន្ទីរ ស្នាដៃសិល្បៈ ឬប្រវត្តិសាស្ត្រ សំណុំសៀវភៅសំខាន់ៗ និងបណ្ណាល័យ ។<br>▪ **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស**<br>ដែលត្រូវបានការពារដោយច្បាប់អន្តរជាតិ ដូចជាមន្ត្រីទូតជាដើម ។ |

# សំណួរទី ២២ | តើចុងចោទមានសិទ្ធិអ្វីខ្លះ ?

ចុងចោទ (ជនសង្ស័យ) មានសិទ្ធិការពារខ្លួននៅក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ។ សិទ្ធិខ្លះនៃសិទ្ធិទាំងអស់នោះ រួមមាន ៖

- សិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ
- សិទ្ធិត្រូវបានគេសន្មតថា មិនមានកំហុស រហូតទាល់តែត្រូវបានគេកាត់សេចក្តីថា មានទោស
- សិទ្ធិជួលមេធាវីទៅតាមការជ្រើសរើសរបស់ពួកគេ
- សិទ្ធិមានពេលវេលាគ្រប់គ្រាន់ និងភាពងាយស្រួលក្នុងការរៀបចំអោយមានមេធាវីរបស់ខ្លួន
- សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើចុងចោទមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីចំណាយទៅលើការជួលមេធាវី និង
- សិទ្ធិត្រួតពិនិត្យសាក្សី ដែលបានចោទប្រកាន់ទៅលើរូបគេ

ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



ជំរុំពលកម្មនៃរបបខ្មែរក្រហមនាពេលមួយ រវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩

បូជនីយដ្ឋានរំលឹកជនរងគ្រោះនៃរបបប្រល័យពូជសាសន៍នៅវាលពិឃាតជើងឯក

## សំណួរទី ២៣

**តើអ្នកណាខ្លះ នឹងកោះអញ្ជើញអោយធ្វើជាសាក្សី ?**

តុលាការនឹងកោះអញ្ជើញសាក្សីអោយមកឆ្លើយបំភ្លឺក្នុងអំឡុងពេលនៃការស៊ើបអង្កេត និងការកាត់ក្តី ។ ជនរងគ្រោះ និងសាក្សីអាចនឹងទទួលនូវការការពារយ៉ាងពិសេសពីតុលាការ (ដូចជា ការបិទទ្វារតុលាការមិនអោយសាធារណជនចូលស្តាប់ការកាត់ក្តី ឬការការពារអត្តសញ្ញាណរបស់ជនរងគ្រោះ ឬសាក្សី) ។ តុលាការនឹងប្រឹងប្រែងសព្វបែបយ៉ាងដើម្បីធានាសន្តិសុខ និងការពារដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការកាត់ក្តីនេះ ជាពិសេសសាក្សី និងជនរងគ្រោះ ។

## សំណួរទី ២៤

**តើខ្ញុំត្រូវផ្តល់ព័ត៌មានទៅអោយតុលាការដែរ ឬទេ ?**

ប្រសិនបើព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេតចង់សម្ភាសជាមួយលោកអ្នក ក្នុងករណីនេះ លោកអ្នកត្រូវតែនិយាយការពិត ។ ទោះជាយ៉ាងណាក៏ដោយ លោកអ្នកមានសិទ្ធិនៅស្ងៀម ប្រសិនបើលោកអ្នកយល់ថាចំលើយអាចធ្វើអោយលោកអ្នកមានជាប់ទាក់ទិននៅក្នុងបទឧក្រិដ្ឋនោះ ។ ហើយលោកអ្នកមានសិទ្ធិស្នើសុំមេធាវី (ស្មាក្តី) ដើម្បីផ្តល់ការប្រឹក្សាដល់លោកអ្នក និងស្ថិតនៅជាមួយលោកអ្នកនៅក្នុងពេលចោទសំណួរ ។ (សូមអានព័ត៌មានដែលទាក់ទងនៅសំណួរទី ៣៧ នៃកូនសៀវភៅនេះ) ។

## សំណួរទី ២៥

**តើធ្វើយ៉ាងដូចម្តេច ប្រសិនបើខ្ញុំចង់ផ្តល់ព័ត៌មានអំពីនរណាម្នាក់ដែលខ្ញុំជឿជាក់ថា បានប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ?**

ពេលណាព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតរៀបចំការិយាល័យរបស់គេនៅតុលាការ ពួកគេនឹងចាប់ផ្តើមស៊ើបអង្កេត ។ ពួកគេនឹងចាប់ផ្តើមធ្វើការសម្ភាសមនុស្សផ្សេងៗគ្នា ។ ប្រសិនបើអ្នកមានព័ត៌មានដែលអ្នកគិតថាវាអាចជួយដល់ព្រះរាជអាជ្ញា ឬអ្នកការពារក្តី ពេលនោះអ្នកអាចទាក់ទងដោយផ្ទាល់ខ្លួននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សូមអានព័ត៌មានដែលមានការទាក់ទងតាមអស័យដ្ឋានលំអិតនៅលើក្របសៀវភៅតូច) ។

## សំណួរទី ២៦

**តើការគាំទ្រអ្វីខ្លះនឹងត្រូវផ្តល់ជូនដល់សាក្សី និងជនរងគ្រោះដែលផ្តល់សក្ខីភាព និងសំរាប់មនុស្សទូទាំងប្រទេស ដែលអាចមានការឈឺចាប់ក្នុងចិត្តនៅពេលស្តាប់ឮពីភស្តុតាងដែលបានបង្ហាញនៅក្នុងតុលាការ ?**

បុគ្គលគ្រប់រូបដឹងហើយថា ពួកគេអាចទទួលរងការឈឺចាប់ក្នុងអារម្មណ៍នៅពេលផ្តល់សក្ខីភាពអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបកម្ពុជា

ប្រជាធិបតេយ្យ ហើយប្រជាជនទូទាំងប្រទេស ដែលមានអនុស្សាវរីយ៍ឈឺចាប់ ខ្លោចផ្សា ពីអ្វីៗដែលបានកើតឡើងចំពោះរូបគេជំនាន់នោះ អាចចាប់ផ្តើមនឹកឃើញឡើងវិញ ។

អង្គជំនុំជម្រះវិសាមញ្ញ នឹងមានការិយាល័យគាំទ្រសាក្សីមួយ ដែលនឹងចាត់ចែងផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រសំរាប់សាក្សីណា ដែលត្រូវការ ។ អ្នកណាក៏ដោយ ដែលស្វែងរកការពិគ្រោះយោបល់ និងការព្យាបាលគប្បីធ្វើការទំនាក់ទំនងនឹងគណៈកម្មាធិការសុខភាពផ្លូវចិត្តនៃក្រសួងសុខាភិបាល ដែលមានការិយាល័យនៅតាមបណ្តាខេត្តនានាទូទាំងប្រទេស ឬអង្គការ ក្រៅរដ្ឋាភិបាលដែលជំនាញឯកទេសផ្នែកនេះ (សូមអានព័ត៌មានទាក់ទងនៅសំណួរទី ៣៧ នៃកូនសៀវភៅនេះ) ។

## សំណួរទី ២៧ | តើជនរងគ្រោះមានសិទ្ធិទទួលសំណងទូទាត់ដែរ ឬទេ ?

នៅក្រោមច្បាប់កម្ពុជាសព្វថ្ងៃ ជនរងគ្រោះអាចទាមទារសំណងក្នុងករណីបណ្តឹងព្រហ្មទណ្ឌ ដែលពួកគេទទួលរងពីបទឧក្រិដ្ឋ ។ វាមិនទាន់ច្បាស់នៅឡើយទេថា តើអង្គជំនុំជម្រះវិសាមញ្ញនឹងដោះស្រាយអំពីការទាមទារសំណងយ៉ាងដូចម្តេច ។ វាមានការលំបាកក្នុងការគិតទុកជាមុនថា តើមានជនរងគ្រោះកម្ពុជាប៉ុន្មានលាននាក់ ដែលត្រូវទទួលសំណងពីជនជាប់ចោទ ដែលត្រូវបានកាត់ទោស ។

## សំណួរទី ២៨ | តើហេតុអ្វីបានជាអង្គការសហប្រជាជាតិចូលរួមពាក់ព័ន្ធ ?

នៅខែ មិថុនា ឆ្នាំ ១៩៩៧ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន សហនាយករដ្ឋមន្ត្រី បានសរសេរលិខិតជូនលោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយស្នើសុំការជួយឧបត្ថម្ភពីអង្គការសហប្រជាជាតិក្នុងដំណើរការកាត់ក្តីបទឧក្រិដ្ឋរបស់ខ្មែរក្រហមនេះ ។ សហនាយករដ្ឋមន្ត្រី បានស្នើសុំការជួយឧបត្ថម្ភខាងលើ ពីព្រោះយល់ឃើញថា វិស័យតុលាការនៅកម្ពុជាខ្វះធនធាន និងជំនាញក្នុងការអនុវត្តន៍កិច្ចការដ៏ស្មុគស្មាញ និងធ្ងន់ធ្ងរបែបនេះ ហើយក៏ដោយសារបទឧក្រិដ្ឋទាំងនោះមានទំហំធំក្រៃលែង ដែលធ្វើអោយមនុស្សទូទាំងពិភពលោកមានការចាប់អារម្មណ៍ខ្លាំង ។

## សំណួរទី ២៩

**តើហេតុអ្វីបានជាអតីតមេដឹកនាំខ្មែរក្រហម មិនត្រូវយកទៅកាត់សេចក្តីនៅទីក្រុងឡាអេ ដែលជាតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ឬក្នុងតុលាការយុត្តិធម៌អន្តរជាតិ ?**

តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងនៅទីក្រុងឡាអេ ប្រទេសហូឡង់ នៅឆ្នាំ ២០០២ ។ កម្ពុជាក៏ជាសមាជិកស្ថាបនិកមួយដែរនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនេះ ប៉ុន្តែតុលាការនេះ អាចធ្វើសវនាការ និងដោះស្រាយតែករណីដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តក្រោយពេលបង្កើតតុលាការនេះនៅឆ្នាំ ២០០២ តែប៉ុណ្ណោះ ។ រីឯតុលាការយុត្តិធម៌អន្តរជាតិកាត់សេចក្តីតែករណីរវាងរដ្ឋ និងរដ្ឋតែប៉ុណ្ណោះ ។

## សំណួរទី ៣០

**តើអង្គជំនុំជម្រះវិសាមញ្ញនេះ គឺជាតុលាការកម្ពុជា ឬជាតុលាការអន្តរជាតិ ?**

អង្គជំនុំជម្រះវិសាមញ្ញនេះ ស្ថិតក្នុងប្រព័ន្ធតុលាការកម្ពុជា ។ ទោះជាយ៉ាងនេះក្តី តុលាការនេះមានលក្ខណៈពិសេសជា “សាលាក្តីចំរុះ ឬតុលាការកូនកាត់” ។ ភាគច្រើននៃមន្ត្រីបំរើការនៅក្នុងតុលាការនេះ គឺបុគ្គលិកកម្ពុជា ។ តុលាការ រួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារទាំងជាតិ និងអន្តរជាតិ ។ ពួកគេទាំងអស់នោះនឹងប្រើប្រាស់ច្បាប់កម្ពុជាផង និងច្បាប់អន្តរជាតិផងដែរ ។

## សំណួរទី ៣១

**តើមានតុលាការផ្សេងទៀតដែរ ឬទេ នៅក្នុងពិភពលោក ដែលមានលក្ខណៈដូចអង្គជំនុំជម្រះវិសាមញ្ញនេះ ?**

តុលាការក្តីចំរុះ ត្រូវបានបង្កើតឡើងនៅពេលកន្លងទៅថ្មីៗនេះ ក្នុងប្រទេសទាំងឡាយមាន សេរ៉ាលេអូន ទីម័រខាងកើត កូសូវ៉ូ ហើយនិងបូស្នៀ ប៉ុន្តែតុលាការនីមួយៗ មានរចនាសម្ព័ន្ធដោយឡែកៗពីគ្នា ។

## សំណួរទី ៣២

**តើហេតុអ្វីបានជាតុលាការប្រភេទនេះ ត្រូវបានយកមកប្រើសំរាប់អង្គជំនុំជម្រះវិសាមញ្ញ ?**

គំរូតុលាការក្តីចំរុះនេះ ត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយដើម្បីផ្តល់ឱកាសអោយមានការចូលរួម និងការពាក់ព័ន្ធយ៉ាងពេញទំហឹងពីសំណាក់ប្រជាជន និងមន្ត្រីកម្ពុជាទូទាំងប្រទេសនៅក្នុងដំណើរការកាត់ក្តីនេះ ហើយទន្ទឹមនឹងនោះ ធានាអោយបានតាមបទដ្ឋានអន្តរជាតិ និងការចូលរួមពីសហគមន៍អន្តរជាតិ ។ សាលាក្តីនេះនឹងមិនប្រព្រឹត្តទៅនៅទីក្រុងឡាអេ ទ្វីបអឺរ៉ុប ដែលស្ថិតនៅឆ្ងាយពីប្រទេសកម្ពុជានោះទេ ។ សាលាក្តីនេះនឹងប្រព្រឹត្តទៅនៅកម្ពុជា ហើយដំណើរការកាត់ក្តីនឹងត្រូវធ្វើឡើងភាគច្រើនជាភាសាខ្មែរ និងបើកចំហអោយមានការចូលរួមពីប្រជាជនកម្ពុជា នឹងត្រូវរាយការណ៍តាមបណ្តាញវិទ្យុ ទូរទស្សន៍ និងសារព័ត៌មានក្នុងស្រុក ។

# សំណួរទី ៣៣ | តើត្រូវចំណាយថវិកាប៉ុន្មានសំរាប់ដំណើរការកាត់ក្តីនេះ ?

ថវិកាសំរាប់ចំណាយក្នុងការកាត់ក្តីនេះ ត្រូវបានគេប៉ាន់ប្រមាណថា អស់ជាង ៦០ លានដុល្លារអាមេរិក ក្នុងរយៈពេល ៣ ឆ្នាំ គឺប្រមាណជា ២០ លានដុល្លារអាមេរិក ក្នុង ១ ឆ្នាំ ។ តួលេខថវិកានេះ មើលទៅដូចជាច្រើនណាស់ ប៉ុន្តែបើធ្វើការប្រៀបធៀបទៅនឹងការចំណាយរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា (សាលាក្តីនីមួយៗចំណាយអស់លើសពី ១០០ លានដុល្លារអាមេរិក ក្នុង ១ ឆ្នាំៗ) និងនៅតុលាការពិសេសសំរាប់ប្រទេសសេរ៉ាលីអូន ការចំណាយអស់ជាង ២៤ លានដុល្លារអាមេរិក ក្នុង ១ ឆ្នាំៗ) ។

# សំណួរទី ៣៤ | តើតុលាការនេះនឹងត្រូវទទួលថវិកាពីប្រភពណា ?

ទាំងរដ្ឋាភិបាលកម្ពុជា និងបរទេស បានចូលរួមវិភាគទានផ្គត់ផ្គង់ដើម្បីចំណាយសំរាប់តុលាការនេះ ។ មូលនិធិពិសេសនេះ មិនត្រូវអោយប៉ះពាល់ ឬកាត់បន្ថយថវិកាជំនួយអន្តរជាតិដទៃទៀតដែលបានផ្តល់អោយដល់ប្រទេសកម្ពុជាសំរាប់ផ្នែកអភិវឌ្ឍន៍ឡើយ ។ ថវិកាសំរាប់ចំណាយក្នុងអង្គជំនុំជម្រះវិសាមញ្ញបែកចេញជាពីរផ្នែក ៖

- ថវិកាដែលទទួលបានតាមរយៈអង្គការសហប្រជាជាតិ ៤៣ លានដុល្លាសហរដ្ឋ ដែលក្នុងនោះ ប្រទេសជប៉ុនបានផ្តល់អោយ ៥០ ភាគរយនៃថវិកាសរុបជាមួយការផ្តល់វិភាគទានពីប្រទេសដទៃទៀត ជាពិសេសមានប្រទេសបារាំង អាល្លឺម៉ង់ ចក្រភពអង់គ្លេស និងអូស្ត្រាលី ។ សូម្បីតែប្រទេសតូចដែលមានប្រវត្តិការឈឺចាប់ដូចកម្ពុជា មានប្រទេសអាមីនីនិងណាមីប៊ី ក៏បានចូលរួមវិភាគទានផងដែរ ។
- ថវិកាតាមរយៈរាជរដ្ឋាភិបាលកម្ពុជា ១៣.៣ លានដុល្លាសហរដ្ឋ ក្នុងនោះ រាជរដ្ឋាភិបាលកម្ពុជា ១.៥ លានដុល្លាសហរដ្ឋ សហគមន៍អឺរ៉ុប ១.២ លានដុល្លាសហរដ្ឋ ឥណ្ឌា ១ លានដុល្លាសហរដ្ឋ និងថៃ ២៥ ពាន់ដុល្លាសហរដ្ឋ ។



ប្រភព ៖ អង្គការសហប្រជាជាតិ

ឯកឧត្តម សុខ អាន (ដែលពេលនោះជាទេសរដ្ឋមន្ត្រី) ជួបជាមួយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ នៅឆ្នាំ ២០០៣ ដើម្បីពិភាក្សាអំពីការបង្កើតតុលាការជម្រះក្តីខ្មែរក្រហម

- បន្ថែមពីលើនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អោយទីតាំង និងអាគារសំរាប់ការិយាល័យរដ្ឋបាល សាលសវនាការ និងចំណាយផ្សេងៗទៀត ដែលគេប៉ាន់ស្មានថាច្រើនជាង ៥ លានដុល្លាសហរដ្ឋ ។ យើងកំពុង និងរៀបចំស្នើសុំថវិកាបន្ថែមពីប្រទេសផ្សេងៗ អង្គការ ក្រុមហ៊ុន មូលនិធិ និងបុគ្គលទាំងឡាយណា ដែលចាប់អារម្មណ៍ការងារអង្គជំនុំជម្រះនេះ ។

## សំណួរទី ៣៥ | តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែម អំពីរឿងខ្មែរក្រហម និងដំណើរការកាត់សេចក្តីនេះដោយវិធីណា ?

### តាមរយៈក្រុមកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញ

សំរាប់ព័ត៌មានបន្ថែម លោកអ្នកអាចទាក់ទងផ្ទាល់នៅសាលាក្តីតាមរយៈផ្នែកកិច្ចការសាធារណៈ ។

លោកអ្នកអាចទំនាក់ទំនងយើងតាមអាស័យដ្ឋាន ៖ តាមបណ្តោយផ្លូវជាតិលេខ៤ ភូមិ អង្គ ឃុំកន្ទោក ស្រុកអង្គស្នួល ។

ទូរស័ព្ទ ៖ (០២៣) ២១៩ ៨១៤
ទូរសារ ៖ (០២៣) ២១៩ ៨៤១
អ៊ីម៉ែល ៖ info@eccc.gov.kh
គេហទំព័រ ៖ www.cambodia.gov.kh/krt/
www.eccc.gov.kh

### តាមរយៈវិទ្យុ និងទូរទស្សន៍

វិទ្យុជាតិកម្ពុជា FM ៩៦ និង AM ៩១៨ និងទូរទស្សន៍ជាតិកម្ពុជា TVK ព្រមទាំងស្ថានីយ៍ផ្សាយដទៃផ្សេងទៀត បានចាប់ផ្តើមការផ្សាយជាទៀងទាត់នូវការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ។

- មណ្ឌលព័ត៌មានស្រ្តីកម្ពុជា ផ្សាយកម្មវិធីជាទៀងទាត់អំពី “មាត៌ាច្បាប់នៅកម្ពុជា” ដែលមានព័ត៌មានជុំវិញរឿងការជំនុំជម្រះអតីតមេដឹកនាំខ្មែរក្រហម ។ កម្មវិធីនេះ ផ្សាយតាមវិទ្យុ FM ១០២ រៀងរាល់ថ្ងៃព្រហស្បតិ៍ ពីម៉ោង ១០ និង ៥០ នាទី ទៅដល់ម៉ោង ១១ និង ៥០ នាទីព្រឹក ហើយចាក់ផ្សាយឡើងវិញនៅថ្ងៃអាទិត្យ ចាប់ពីម៉ោង ៦ និង ៣០ នាទី ទៅដល់ម៉ោង ៧ ព្រឹក ។
- មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ធ្វើការផ្សាយផងដែរនៅទូទាំងប្រទេស ។
- ភ្នំពេញ, រៀងរាល់ថ្ងៃពុធ និងព្រហស្បតិ៍ ចាប់ពីម៉ោង ៧ និង ៣០ នាទី ដល់-ម៉ោង ៧ និង ៤៥ ល្ងាច តាមវិទ្យុ FM ១០២ ។
- កំពត, ប្រចាំថ្ងៃចាប់ពីម៉ោង ៧ ដល់ម៉ោង ៧ និង ៣០ នាទីព្រឹក និងចាប់ពីម៉ោង ៧ ដល់ម៉ោង ៧ និង ៣០ នាទីល្ងាច តាមវិទ្យុ FM ៩៣.២៥ ។
- ព្រះវិហារ, ប្រចាំថ្ងៃ ចាប់ពីម៉ោង ៧ ដល់ម៉ោង ៧ និង ៣០ នាទីព្រឹក និងពីម៉ោង ៦ និង ៣០ នាទី ដល់ម៉ោង ៧ល្ងាច តាមវិទ្យុ FM ៩៩ ។

- បាត់ដំបង, ប្រចាំថ្ងៃចាប់ពីម៉ោង ៩ ដល់ម៉ោង ៩ និង ៣០នាទីព្រឹក និងចាប់ពីម៉ោង ៣ ដល់ម៉ោង ៣ និង ៣០នាទីល្ងាចតាមវិទ្យុ FM ១០៣.២៥ ។
- ហើយនិងមានការពង្រីកកម្មវិធីផ្សាយនៅខេត្តសៀមរាបនៅពេលឆាប់ៗនេះ ។

## តាមរយៈឯកសារ

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតបណ្ណាល័យសាធារណៈនៅទីក្រុងភ្នំពេញ ។ ប្រជាជនអាចមកស្វែងយល់ព័ត៌មានតាមរយៈឯកសារ សៀវភៅ រូបថត ទស្សនាវដ្ដី និងវីឌីអូ ដែលទាក់ទងរឿងអតីតកាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅ និងទស្សនាវដ្ដីឈ្មោះ ស្វែងរកការពិត រួចចែកផ្សាយទូទាំងប្រទេស ។

## តាមរយៈអ៊ីនធឺណិត

លោកអ្នកអាចស្វែងរកព័ត៌មានទាន់ហេតុការណ៍ ដែលទាក់ទងនឹងរឿងការជំនុំជម្រះក្ដីអតីតមេដឹកនាំខ្មែរក្រហមគេហទំព័រ ៖ www.eccc.gov.kh និងជាមួយក្រុមការងាររបស់រាជរដ្ឋាភិបាលកម្ពុជា www.cambodia.gov.kh/krt/ ហើយនិងជំនួយការអង្គការសហប្រជាជាតិសំរាប់ការជំនុំជម្រះខ្មែរក្រហម www.un.org/law/khmerrougetrials/ គេហទំព័រផ្សេងទៀត ដែលមានទំនាក់ទំនងជាមួយរឿងក្ដីខ្មែរក្រហម រួមមាន ៖

- មជ្ឈមណ្ឌលឯកសារកម្ពុជា www.dccam.org
- កម្មវិធីស្រាវជ្រាវការប្រល័យពូជសាសន៍នៅកម្ពុជារបស់សកលវិទ្យាល័យយ៉េល www.cgp.org
- ក្រុមតាមដានអំពីប្រល័យពូជសាសន៍ www.genocidewatch.org
- វេទិកាសាធារណៈ www.krtrials.org.kh

## សំណួរទី ៣៦ | តើអង្គការក្រៅរដ្ឋាភិបាលមានតួនាទីអ្វីខ្លះក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ?

អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិជាច្រើន មានការចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការកាត់សេចក្ដីខ្មែរក្រហម ហើយនិងធ្វើការគាំទ្រតាមមធ្យោបាយផ្សេងៗគ្នា ។ ឧទាហរណ៍ អង្គការខ្លះនឹងជួយគាំទ្រដល់សាក្សីនិងជនរងគ្រោះជាមួយនឹងការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រ ហើយអង្គការខ្លះទៀតនឹងជួយផ្សព្វផ្សាយនូវដំណើរការនៃការកាត់ក្ដី ឬជួយផ្នែកបណ្ដុះបណ្ដាល ឬការផ្ដល់ឱវាទ និងតំណាងកូនក្ដី ។

## សំណួរទី ៣៧ | តើខ្ញុំអាចទទួលសេវាកម្មគាំទ្រសំរាប់រូបខ្ញុំនៅទីណាបាន ?

### អង្គការគាំទ្រ និងផ្ដល់ជំនួយផ្នែកច្បាប់

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
**Cambodian Defenders Project (CDP)**
ផ្ទះលេខ ១២ ផ្លូវលេខ ២៨២ ភ្នំពេញ

លេខទូរស័ព្ទ : ០២៣ ៧២០ ០៣២
លេខទូរសារ : ០២៣ ៧២០ ០៣១
សារអេឡិចត្រូនិច : cdp@cdpcambodia.org

### គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
***Cambodian Human Rights Committee (CHRC)***

ផ្ទះលេខ ២៧៤ មហាវិថីព្រះមុនីវង្ស ភ្នំពេញ
លេខទូរស័ព្ទ : ០២៣ ២១១ ១៦២
លេខទូរសារ : ០២៣ ២២១ ៨៤៧

### ជំនួយផ្នែកច្បាប់នៃកម្ពុជា
***Legal Aid of Cambodia (LAC)***

ផ្ទះលេខ ៤៣ ផ្លូវលេខ ៣០៦ បឹងកេងកង១
ខណ្ឌចំការមន ភ្នំពេញ
លេខទូរស័ព្ទ : ០២៣ ២១៤ ៨២៤
លេខទូរសារ : ០២៣ ២១២ ២០៦
សារអេឡិចត្រូនិច : lac@online.com.kh

### សមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
***Cambodia Human Rights and Development Association (ADHOC)***

ផ្ទះលេខ ៣ ផ្លូវលេខ ១៥៨ បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ
លេខទូរស័ព្ទ និងទូរសារ : ០២៣ ៩៩០ ៥៤៤
សារអេឡិចត្រូនិច : adhoc@forum.org.kh

### សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
***Cambodian League for the Promotion and Defense of Human Rights (Licadho)***

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ បឹងត្របែក
ប្រអប់សំបុត្រលេខ : ៤៩៩ ភ្នំពេញ
លេខទូរស័ព្ទ និងទូរសារ : ០២៣ ៣៦០ ៩៦៥
សារអេឡិចត្រូនិច : licadho@camnet.com.kh

### គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
***The Bar Association of the Kingdom of Cambodia (BAKC)***

ផ្ទះលេខ ១០-១១ ផ្លូវកាកបាទក្រហមខ្មែរ (ផ្លូវលេខ ១៨០)
បឹងរាំង ដូនពេញ ភ្នំពេញ
ប្រអប់សំបុត្រលេខ : ១៥៨៧
លេខទូរស័ព្ទ : ០២៣ ២២០ ២៣៧
លេខទូរសារ : ០២៣ ២១៣ ៦៥៨

## អង្គការសំរាប់ទំនាក់ទំនង និងផ្តល់ព័ត៌មានជាសាធារណៈ

### គំរោងយុត្តិធម៌នៅកម្ពុជា
***Cambodia Justice Initiative (CJI)***

មណ្ឌលភ្នំពេញ ជាន់ទី២ បន្ទប់លេខ ២២២
លេខទូរស័ព្ទ និងទូរសារ : ០២៣ ២២១ ៧៩៣
សារអេឡិចត្រូនិច : cji@online.com.kh

### វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា
***The NGO Forum on Cambodia***

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦,
ប្រអប់សំបុត្រលេខ : ២២៩៥
លេខទូរស័ព្ទ : ០២៣ ២១៤ ៤២៩ - ០១២ ៧១០ ០៣៧
លេខទូរសារ : ០២៣ ៩៩៤ ០៦៣
សារអេឡិចត្រូនិច : ngoforum@ngoforum.org.kh

### គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
***Cambodian Human Rights Action Committee (CHRAC)***

ផ្ទះលេខ ៣ ផ្លូវលេខ ១៥៨ បឹងរាំង ដូនពេញ
ប្រអប់សំបុត្រលេខ : ៤៩៩ ភ្នំពេញ
លេខទូរស័ព្ទ និងទូរសារ : ០២៣ ៣៥១ ៤១៥
សារអេឡិចត្រូនិច : chrac@forum.org.kh

### មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា
***Women's Media Center of Cambodia (WMC)***

ផ្ទះលេខ ៣០ ផ្លូវលេខ ៤៨៨/៤៨៤ ភ្នំពេញ
លេខទូរស័ព្ទ និងទូរសារ : ០២៣ ២២៣ ៥៩៧
សារអេឡិចត្រូនិច : wmc@online.com.kh

### មជ្ឈមណ្ឌលឯកសារកម្ពុជា
***Documentation Center of Cambodia (DC-Cam)***

ផ្ទះលេខ ៦៦c មហាវិថីព្រះសីហនុ ភ្នំពេញ
លេខទូរស័ព្ទ : ០២៣ ២១១ ៨៧៥
លេខទូរសារ : ០២៣ ២១០ ៣៥៨
សារអេឡិចត្រូនិច : dccam@online.com.kh

### មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម
***Center for Social Development (CSD)***

ផ្ទះលេខ ១៩ ផ្លូវលេខ ៥៧ សង្កាត់បឹងកេងកង១
ខណ្ឌចំការមន ភ្នំពេញ
លេខទូរស័ព្ទ : ០២៣ ៣៦៤ ៧៣៥
លេខទូរសារ : ០២៣ ៣៦៤ ៧៣៦
សារអេឡិចត្រូនិច : info@csdcambodia.org

### វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ
***Khmer Institute for Democracy (KID)***

ផ្ទះលេខ ៥ ផ្លូវលេខ ៥៧ ភ្នំពេញ
លេខទូរស័ព្ទ : ០២៣ ២១៤ ៩២៨
លេខទូរសារ : ០២៣ ២១៦ ២០៦
សារអេឡិចត្រូនិច : director.kid@online.com.kh

## អង្គការពិគ្រោះយោបល់ និងសេវាសុខភាពផ្លូវចិត្ត

### ចេស្វីតសឺវីសកម្ពុជា ***Jesuit Service Cambodia (JSC)***

ផ្ទះលេខ ៩៦ ផ្លូវលេខ ៥៩២ ខណ្ឌទួលគោក ភ្នំពេញ

លេខទូរស័ព្ទ ៖ ០២៣ ៨៨០ ១៣៩
លេខទូរសារ ៖ ០២៣ ៨៨០ ១៤០
សារអេឡិចត្រូនិច ៖ jrscam@forum.org.kh

**សេវាសង្គមកិច្ចកម្ពុជា (សសក)**
ផ្ទះលេខ ២ ផ្លូវ ២៨៩ ភ្នំពេញ
ប្រអប់សំបុត្រលេខ ៖ ១៤៧៧
លេខទូរស័ព្ទ ៖ ០២៣ ៨៨១ ៤៣២ - ០២៣ ៨៨១ ៥៣២
លេខទូរសារ ៖ ០២៣ ៨៨១ ៤៣០
សារអេឡិចត្រូនិច ៖ ssc@online.com.kh

**សេវាសង្គមកិច្ចកម្ពុជា ខេត្តកំពង់ស្ពឺ**
ភូមិភ្នំដី ឃុំច្បារមន ស្រុកច្បារមន ផ្លូវជាតិលេខ ៤
លេខទូរស័ព្ទ ៖ ០១២ ៨០៣ ៥៣៣

**សេវាសង្គមកិច្ចកម្ពុជា ខេត្តឧត្តរមានជ័យ/ សៀមរាប**
ភូមិអូរក្រវ៉ាន់ ឃុំសំរោង ស្រុកសំរោង
លេខទូរស័ព្ទ ៖ ០១២ ៣៣៣ ១០៣
សារអេឡិចត្រូនិច ៖ 012333103@mobitel.com.kh

**អង្គការកម្មវិធីសុខភាពផ្លូវចិត្ត**
ផ្ទះលេខ ២០ ផ្លូវលេខ ៣៣៤ ភ្នំពេញ
ប្រអប់សំបុត្រលេខ ៖ ១១២៤
លេខទូរស័ព្ទ ៖ ០២៣ ២១៩ ១៨២
លេខទូរសារ ៖ ០២៣ ២១៨ ៤៧៨
សារអេឡិចត្រូនិច ៖ admin@tpocambodia.org

**អង្គការកម្មវិធីសុខភាពផ្លូវចិត្ត ខេត្តពោធិសាត់**
ផ្លូវលេខ ៣ ភូមិពាលញែកទី ១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស
លេខទូរស័ព្ទ ៖ ០៥២ ៩៥១ ៥៥៥
សារអេឡិចត្រូនិច ៖ tpops@camintel.com

**អង្គការកម្មវិធីសុខភាពផ្លូវចិត្ត ខេត្តបាត់ដំបង**
ផ្ទះលេខ ១២២ ផ្លូវលេខ ៥ ក្រុមទី ១៤ ភូមិរំចេកទី ៤
ឃុំរតនៈ ស្រុកបាត់ដំបង
លេខទូរស័ព្ទ ៖ ០៥៣ ៩៥២ ៣៤៣
សារអេឡិចត្រូនិច ៖ tpobtb@camintel.com

**អង្គការកម្មវិធីសុខភាពផ្លូវចិត្ត រតនៈមណ្ឌល (ខេត្តបាត់ដំបង)**
ផ្ទះលេខ ១១ ផ្លូវលេខ ១០ ភូមិស្ពោ ឃុំស្ពោ
ស្រុករតនៈមណ្ឌល
លេខទូរស័ព្ទ ៖ ០១២ ២២៩ ៩០២
សារអេឡិចត្រូនិច ៖ 012229902@mobitel.com.kh

**អង្គការកម្មវិធីសុខភាពផ្លូវចិត្ត ខេត្តបន្ទាយមានជ័យ**
ផ្លូវលេខ ៣ ភូមិសូភី ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ
លេខទូរស័ព្ទ ៖ ០៥៤ ៩៥៨ ៩១០
សារអេឡិចត្រូនិច ៖ tpobmc@camintel.com

**អង្គការកម្មវិធីសុខភាពផ្លូវចិត្ត ខេត្តកំពង់ធំ**
ផ្ទះលេខ ៣៦ ភូមិទី ៧
ឃុំកំពង់ធំ ស្រុកស្ទឹងសែន
លេខទូរស័ព្ទ ៖ ០៦២ ៩៦១ ៣៧៥
សារអេឡិចត្រូនិច ៖ tpoktp@camintel.com

## សេវាសុខភាពផ្លូវចិត្តរបស់រដ្ឋាភិបាល

**បន្ទាយមានជ័យ ៖** មន្ទីរពេទ្យមង្គលបូរី ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
ភូមិកោះកែវ ឃុំប្ញស្សីក្រោក
វេជ្ជ. វ៉ាន់ លុច ៖ ០១២ ៦០០ ៣២១

**បាត់ដំបង ៖** មន្ទីរពេទ្យបង្អែកបាត់ដំបង ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ
វេជ្ជ. ឈិត សុផល ៖ ០១២ ៧៧៧ ២១៨

**កំពង់ចាម ៖** មន្ទីរពេទ្យបង្អែកកំពង់ចាម ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
វេជ្ជ. សម សង្វាត ៖ ០១២ ៩៨៣ ៥៩៥
០១២ ៨៩២ ០៩២

**កំពង់ស្ពឺ ៖** មន្ទីរពេទ្យបង្អែកខត្តុង ផ្នែកសុខភាពផ្លូវចិត្ត
លោក គីម សុភាព ៖ ០១២ ៩១០ ០៦២

**កំពង់ស្ពឺ ៖** សេវាសង្គម និងសុខភាពផ្លូវចិត្ត ផ្លូវជាតិលេខ ៤
(នៅខាងលិចផ្សារកំពង់ស្ពឺ ៣ គ.ម)
លោកស្រី ហេង ស្រី ៖ ០១២ ៨០៣ ៥៣៣

**កំពង់ធំ ៖** មន្ទីរពេទ្យបង្អែកកំពង់ធំ ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
វេជ្ជ. អ៊ិត ប៊ុនគី ៖ ០១១ ៨៦៤ ៨៨៧

**កណ្តាល ៖** មន្ទីរពេទ្យជ័យជំនះ មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ
ផ្ទះលេខ ៤៧ ផ្លូវ ១៩៨ ក្រុងតាខ្មៅ
លេខទូរស័ព្ទ ៖ ០២៣ ២១០ ៧៥៧
លេខទូរសារ ៖ ០២៣ ២១៦ ២៥៨
វេជ្ជ. ឡោ វណ្ណថាវី ៖ ០១៦ ៨៣៨ ៣៣៩

**ភ្នំពេញ ៖** មន្ទីរពេទ្យព្រះបាទនរោត្តមសីហនុ ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
លោកសាស្ត្រាចារ្យ ការ ស៊ុនបូណាត ៖ ០១២ ៨៦៥ ៤៤០
វេជ្ជ. អាង សូឌី ៖ ០១២ ៦២២ ៤៨៧

**កំពត ៖** មន្ទីរពេទ្យបង្អែកកំពត ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
ក. ចាប សុជាតា ៖ ០១២ ៧០០ ១៦៧

**ពោធិសាត់ ៖** មន្ទីរពេទ្យបង្អែកខេត្តពោធិសាត់ សេវាសុខភាពផ្លូវចិត្ត
វេជ្ជ. តេង ហុកលី ៖ ០១២ ៩៨៩ ៣០៦

**ព្រះវិហារ ៖** មន្ទីរពេទ្យបង្អែកព្រះវិហារ ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
វេជ្ជ. ដូ ប៉ូលីណា ៖ ០១២ ៩៦៨ ៣២៨

**សៀមរាប ៖** មន្ទីរពេទ្យបង្អែកសៀមរាប ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
លោក សុខ ចំរើន ៖ ០១២ ៧៨២ ០០៥

**ស្វាយរៀង ៖** មន្ទីរពេទ្យបង្អែកស្វាយរៀង ផ្នែកពិគ្រោះជំងឺផ្លូវចិត្ត
វេជ្ជ. សូ បូរាណ ៖ ០១១ ៦៣៨ ៣០៧

ISBN: 99950-73-00-5

# ការិយាល័យកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ភូមិ អង្គ ឃុំ កញ្ជែក ស្រុក អង្គស្នួល តាមផ្លូវជាតិលេខ ៤

ទូរស័ព្ទ : ០២៣ ២១៩ ៨១៤ ទូរសារ : ០២៣ ២១៩ ៨៤១ - អ៊ីម៉ែល : info@eccc.gov.kh

គេហទំព័រ : www.cambodia.gov.kh/krt/
www.eccc.gov.kh

Australian Government
AusAID
ទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍអន្តរជាតិ

ការបោះពុម្ពផ្សាយអំពីលេខាធិការដ្ឋាន
ក្រុមការងារសំរាប់ការកាត់ទោសខ្មែរក្រហម
ដោយមានការគាំទ្រពីអ្នកផ្តល់ជំនួយ

UNIVERSITY OF OSLO
Norwegian Centre for Human Rights
សាកលវិទ្យាល័យ អូស្លូ
មជ្ឈមណ្ឌលសិទ្ធិមនុស្ស ន័រវេស

Design by Graphic Roots: www.graphicroots.com.kh